# ព្រះវិហារវត្តពោធិហាន់ជ័យលើ

វត្តពោធិហាន់ជ័យលើមិនត្រឹមតែជាទីសក្ការបូជាសម្រាប់ពុទ្ធសាសនិកប៉ុណ្ណោះទេ តែទីអារាមនេះគឺជាតឹកតាងសិល្បៈស្ថាបត្យកម្មដ៏ល្អមួយ ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៧៣ ក្នុងឃុំហាន់ជ័យលើ ស្រុកឆ្លូង ខេត្តក្រចេះ។ វត្តនេះស្ថិតក្នុងភូមិសាស្ត្រយ៉ាងប្រពៃនៅប្រៀបតាមដងទន្លេមេគង្គ ដូចបណ្តាវត្តបុរាណផ្សេងៗទៀតដែរ។ បើយោងតាមលទ្ធផលនៃការសិក្សារបស់អ្នកស្រាវជ្រាវ ព្រះវិហារវត្តពោធិហាន់ជ័យលើបានសាងឡើងនៅភាគខាងចុងសម័យអាណាព្យាបាលបារាំង។ អ្វីជាការកត់សម្គាល់នោះទោះបីជាពេលវេលាបានកន្លងផុតទៅរាប់សិបឆ្នាំ ឆ្លងកាត់សង្គ្រាម និងការផ្លាស់ប្តូររបបនយោបាយជាច្រើនដំណាក់កាល ក៏សំណង់ព្រះវិហារនេះនៅតែរក្សាបានរចនាសម្ព័ន្ធដើមយ៉ាងរឹងមាំ។ ភាពរឹងមាំនៃសំណង់ព្រះពុទ្ធសាសនានេះ សបញ្ជាក់ឱ្យឃើញពីបច្ចេកទេសសាងសង់ដោយផ្ចិតផ្ចង់ និងការជ្រើសរើសគ្រឿងបង្គុំសំណង់ប្រកបដោយគុណភាពខ្ពស់របស់បុព្វបុរសជំនាន់មុន បន្សល់សម្រាប់ការគោរពបូជាដល់សព្វថ្ងៃ (រូបលេខ១)។



រូបលេខ១ ព្រះវិហារវត្តពោធិហាន់ជ័យលើមើលពីជ្រុងម្ខាង

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ព្រះវិហារវត្តពោធិហាន់ជ័យលើ សាងឡើងលើខឿនខ្ពស់៣ថ្នាក់ ក្នុងរចនាបថជាស្ថាបត្យកម្មខ្មែរមួយបែប ដែលមានផ្នែកខ្លះទទួលឥទ្ធិពលសិល្បៈប៉ែកអឺរ៉ុប។ ផ្នែកខាងក្រៅព្រះវិហារ បើមើលជាក់ស្តែងលើរចនាសម្ព័ន្ធដំបូល គេចាត់ជាទម្រង់ព្រះវិហារជហ្វាបួន ឬហៅថាទម្រង់ដំបូលព្រះវិហារបុរាណ (រូបលេខ២២)។[1] ដំបូលប្រក់ដោយក្បឿងស្រកាលេញ ជ្រាលចុះជាថ្នាក់ៗ ហើយផ្នែកខ្លះនៃដំបូលក៏ធ្លាប់បានជួសជុលថែរក្សាមកជាហូរហែដែរ។ នៅតាមចុងចែងដំបូលនីមួយៗ មានបំពាក់លម្អដោយក្បាលនាគចែងជាប្រភេទសិល្បៈចម្លាក់ពុម្ពស៊ីម៉ងត៍។

ដូចបានពោលមកពីខាងដើម អ្វីជាលក្ខណៈពិសេសនៃរចនាសម្ព័ន្ធព្រះវិហារវត្តពោធិហាន់ជ័យលើ គឺទេពកោសល្យនៃការបញ្ចូលនូវផ្នែកខ្លះក្នុងរចនាបថសិល្បៈអឺរ៉ុបនៅលើសំណង់ព្រះវិហារបង្កើតជាយ៉ព័ទ្ធជុំវិញត្រង់ផ្នែកខាងលើនៃសសរបាំងសាច ស្រដៀងនឹងព្រះវិហារវត្តកៀនឃ្លាំង ស្ថិតក្នុងតំបន់ជ្រោយចង្វារ រាជធានីភ្នំពេញ។ មិនតែប៉ុណ្ណោះ នៅតាមចន្លោះសសរលើយ៉ទាំងនោះទៀតសោត លោកកសាងផ្ទៃជញ្ជាំងខ្វៀ(?)ឱ្យមានរាងកោងផ្កាប់ស្មើរដូចដងធ្នូ ឬគេនិយមហៅថារាងជាអក្សរអ៊ុយ(U)ផ្កាប់។ ផ្នែកខាងក្រោមនៃយ៉ជុំវិញនោះ មានលម្អដោយទេនទយរូបគ្រុឌ និងកិន្នរនៅតាមសសរនីមួយៗ។ រចនាសម្ព័ន្ធផ្នែកនេះ ហាក់ជួយបង្កើនសោភ័ណភាពសំណង់ និងបង្ហាញពីទឹកដៃសិល្បៈយ៉ាងល្អវិចិត្រក្រៃលែង (រូបលេខ២៣)។



រូបលេខ២២ រចនាសម្ព័ន្ធដំបូលព្រះវិហារវត្តពោធិហាន់ជ័យលើមើលពីចំហៀង



រូបលេខ២៣ រចនាសម្ព័ន្ធយ៉នៃសសរបាំងសាចជុំវិញព្រះវិហារ ដែលមានការបញ្ចូលទម្រង់សិល្បៈអឺរ៉ុប

[1] ព្រាប ចាន់ម៉ារ៉ា, ២០១៧: ១៣-២៣

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ចំពោះក្បាច់លម្អលើហោជាងទាំងពីរនៃព្រះវិហារនេះ គឺមានលក្ខណៈស្ទើរដូចគ្នា ពោលគឺជាទម្រង់ក្បាច់ភ្ញីទេស លាបរំលេចពណ៌ទឹកមាសគ្រប់ផ្នែក លម្អលើផ្ទៃហោជាងទាំងមូល តែពុំមានចំណារចារឹកអ្វីជាសម្គាល់ឡើយ។ ហោជាងខាងមុខ(រូបលេខ២) នៅត្រង់ផ្នែកកណ្ដាល គឺជារូបជើងពានទ្រគម្ពីរ ឬព្រះខ័ន(?) ព័ទ្ធជុំវិញដោយសន្ទឹកក្បាច់យ៉ាងរស់រវើក។ ហោជាងខាងក្រោយ(រូបលេខ៣) ក៏បង្ហាញពីភាពរស់រវើកនៃក្បាច់ភ្ញីទេសពេញលើផ្ទៃហោងជាងដែរ។ ប៉ុន្តែនៅផ្នែកកណ្ដាលហោជាង មានរូបទេវតាចំនួន ៣អង្គ ស្ថិតក្នុងឥរិយាបថប្រណមចេញពីសន្ទឹកក្បាច់។ ទេពមួយអង្គខាងលើស្ថិតក្នុងឥរិយាបថបង្ហាញត្រឹមពាក់កណ្ដាលខ្លួនចេញពីផ្កាឈូក និងពាក់មកុដស្រួចៗ។ ចំណែកទេពពីរអង្គទៀតនៅអមសងខាងនៃផ្នែកខាងក្រោម ក៏ស្ថិតក្នុងកាយវិការសំពះប្រណមបែរកគ្នា។



រូបលេខ២ ហោជាងខាងមុខ



រូបលេខ៣ ហោជាងខាងក្រោយ

ចំណែកការលម្អផ្នែកខាងក្រៅព្រះវិហារ គេសង្កេតឃើញនៅតាមទ្វារ និងបង្អួចនីមួយៗលម្អដោយក្បាច់ពុម្ពស៊ីម៉ងត៍យ៉ាងរស់រវើកព័ទ្ធជុំវិញ។ ក្បាច់លម្អផ្នែកខាងលើទ្វារ និងបង្អួចទាំងអស់ រចនាជារាងស្ទើរពាក់កណ្ដាលរង្វង់ ដែលមានទងក្បាច់រំលេចចេញពីក្បាលខាប ដែលតែងឃើញនិយមប្រើក្នុងក្បាច់ភ្ញីទេស។[2] រីឯនៅតាមក្បាលសសរទ្រយ៉ជុំវិញព្រះវិហារលម្អដោយទេនទយគ្រុឌ និងកិន្នរ ហើយនៅតាមជើងជញ្ជាំងខឿនទី១ និងជញ្ជាំងខឿនទី២ មានលម្អដោយក្បាច់តាមថ្នាក់ដូចជា ពេជ្រមូល (តូច-ធំ) ឈូកផ្កាប់ និងលំហួតជាដើម (រូបលេខ៤-៦)។

[2] ច័ន្ទ វិត្ថារិទ្ធ, ២០០៩: ៨៧-៩២

អត្ថបទដោយៈ ហៀន សុវណ្ណមរកត







រូបលេខ៦-៨ រចនាសម្ព័ន្ធជុំវិញព្រះវិហារ និងការលម្អលើទ្វារ បង្អួច ក្បាលសសរ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ដោយឡែកនៅផ្នែកខាងក្នុងព្រះវិហារ ជាលំហស្រឡះដែលចែកជាល្វែងគ្រឹះនៅចំកណ្ដាលអមដោយរបៀងសងខាង ហើយសាងបល្ល័ង្កព្រះដីរ៍នៅចុងល្វែងគ្រឹះម្ខាង តម្កល់ព្រះពុទ្ធបដិមាកាយវិហារផ្ចាញ់មារ (រូបលេខ៩)។ នៅចំហៀងទាំងសងខាងនៃខឿន បល្ល័ង្កនោះ លោកគូរបង្ហាញទិដ្ឋភាពនរកក្នុងសភាពផ្សេងៗទៅតាមហេតុនៃទោស (រូបលេខ១០-១១)។ ការគូរបង្ហាញអំពីទោសសត្វនរកលើបល្ល័ង្កបែបនេះ ក៏ឃើញនៅបណ្ដាព្រះវិហារផ្សេងដូចជាព្រះវិហារចាស់វត្តរកាអារជាដើម។



រូបលេខ៩ ព្រះពុទ្ធបដិមាធំតម្កល់ក្នុងព្រះវិហារវត្តពោធិហាន់ជ័យលើ

KHMER CIVILIZATION



រូបលេខ១០ គំនូរបង្ហាញពីពពួកសត្វនរកលើខឿនបល្ល័ង្កព្រះដីរ៍

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



*រូបលេខ១១ គំនូរបង្ហាញពីពពួកសត្វនរកលើខឿនបល្ល័ង្កព្រះជីវ៍*

សិល្បៈគំនូរលើជញ្ជាំងនិងពិតានខាងក្នុងព្រះវិហារនៃវត្តពោធិហាន់ជ័យលើ គឺជាគំនូរសាងថ្មី ដ្បិតមានចំណារកត់ចំណាំខុសៗគ្នាដោយអន្ទើ ដែលទំនងសាងឡើងជាពីរដំណាក់កាល។ តាមចំណារលើបល្ល័ង្កព្រះជីវ៍ និងលើជញ្ជាំងកត់ចំណាំក្នុងឆ្នាំ១៩៩០ តែចំណារលើពិតានកត់ចំណាំក្នុងឆ្នាំ២០២៤ ដែលអាចបញ្ជាក់ពីដំណាក់កាលនៃការជួសជុលព្រះវិហារក្រោយសម័យសង្គ្រាម ដ្បិតតាមការសន្និដ្ឋានរបស់អ្នកស្រាវជ្រាវ Danielle & Dominique-Pierre Guére បញ្ជាក់ថា ព្រះវិហារនេះបានកសាងតាំងពីឆ្នាំ១៩២៨។[3]

សាច់រឿងគំនូរលើជញ្ជាំងបានសាងឡើងជា៣បន្ទាត់ រៀបរាប់រឿងពុទ្ធប្រវត្តិ និងរឿងជាតក។ គំនូរលើបន្ទាត់ជួរទី១ និងជួរទី២ ចាប់ផ្ដើមសាច់រឿងតាំងពីព្រះអង្គនិមន្តចុះមកចាប់បដិសន្ធិ រហូតដល់បរិនិព្វាន។ សាច់រឿងចាប់ផ្ដើមពីលេខរៀងទី១ "ទ្រង់និមន្តទេវបុត្ត" នៅលើជញ្ជាំងខាងជើងជ្រុងខាងលិច។ ចំណែកផ្ទាំង "ទ្រង់ចូលបរិនិព្វាន" ស្ថិតនៅចំពីមុខព្រះជីវ៍ (រូបលេខ១២)។ ចំណែកឯគំនូររឿងជាតក ចាប់ផ្ដើមពីមហាវេស្សន្តរជាតកពីកណ្ឌទី១ "ទសពរ" នៅជញ្ជាំងខាងស្ដាំព្រះជីវ៍ និងបញ្ចប់ដល់កណ្ឌទី១៣ ទើបបន្តដោយរឿងទសជាតកផ្សេងៗទៀតដូចជា តេមិយជាតក ព្រះវិធូរ រហូតដល់ជាតកទី១០ គឺ "ព្រះវេស្សន្តរដាក់ទាន" (រូបលេខ១៣)។ ប៉ុន្តែសាច់រឿងគំនូរលើពិតាន លើកអន្ទើក្នុងរឿងពុទ្ធប្រវត្តិដោយអន្ទើខ្លះដូចជា ទ្រង់នាំអានន្ទទៅមើលស្រីសួគ៌ ព្រះពុទ្ធ៥ព្រះអង្គ និងទ្រង់បិណ្ឌបាត្រជាដើម។

[3] Danielle & Dominique-Pierre Guéret; 2017, p. 116

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត




*រូបលេខ១២-១៣ គំនូរលើជញ្ជាំងព្រះវិហារ "ព្រះអង្គបរិនិព្វាន" និងគំនូររឿងជាតក "មហាវេស្សន្តរជាតក"*

ជារួមមក ព្រះវិហារវត្តពោធិហាន់ជ័យលើ គឺជាសក្ខីភាពនៃសិល្បៈស្ថាបត្យកម្មខ្មែរដ៏វិចិត្រនាសម័យអាណាព្យាបាលបារាំង ដែលបានរួមបញ្ចូលគ្នាយ៉ាងល្អនូវទម្រង់បុរាណ និងឥទ្ធិពលសិល្បៈអឺរ៉ុប។ ទោះបីជាបានឆ្លងកាត់ការផ្លាស់ប្តូររបបនយោបាយ និងសង្គ្រាមជាច្រើនដំណាក់កាលក៏ដោយ ក៏សំណង់នេះនៅតែរក្សាបាននូវរចនាសម្ព័ន្ធដើមយ៉ាងរឹងមាំ ដែលសបញ្ជាក់ពីបច្ចេកទេសសាងសង់ដ៏ផ្ចិតផ្ចង់របស់បុព្វបុរសខ្មែរ។ ក្រៅពីតម្លៃផ្នែកស្ថាបត្យកម្ម ទីអារាមនេះក៏ជាផ្ទាំងទស្សនីយភាពនៃសិល្បៈគំនូរពុទ្ធប្រវត្តិ និងរឿងជាតក ដែលបង្កប់នូវតម្លៃអប់យ៉ាងជ្រាលជ្រៅសម្រាប់ពុទ្ធសាសនិក និងជាបេតិកភណ្ឌវប្បធម៌ដ៏មានតម្លៃនៅប្របតាមដងទន្លេមេគង្គ ក្នុងខេត្តក្រចេះ។

## ឯកសារយោង

ច័ន្ទ វិត្ថារិទ្ធ,

២០០៥, *ក្បាច់ខ្មែរ*, រៃយំ, ភ្នំពេញ

ព្រាប ចាន់ម៉ារ៉ា,

២០១៧, *សំណង់នៅតាមវត្ត*, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ

Danielle & Dominique-Pierre Guéret

2017, *The Khmer Pagoda*, KAM Edition, Phnom Penh

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

AMS អរិយធម៌ខ្មែរ KHMER CIVILIZATION